**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៥១ អ.ក ចុះថ្ងៃទី ០២
ខែ កុម្ភៈ ឆ្នាំ ២០០០
សាលក្រម
លេខ : ៣១ (ក) ចុះថ្ងៃទី ៣០
ខែ ឧសភា ឆ្នាំ ២០០០

សាលក្រមនេះក្លាយជាសាលក្រមស្ថាពរចាប់ពីថ្ងៃ ៣១-០៧- ២០០០ នេះតទៅដោយគូភាគី ពុំបានចូលប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

កណ្តាល,ថ្ងៃទី ៣១ ខែ ០៧ ឆ្នាំ ២០០០
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ប្រធានតុលាការខេត្ត**
[redacted]

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីអំពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នាទីតុលាការខេត្តកណ្តាលនៅថ្ងៃទី ៣០ ខែ ឧសភា កុម្ភៈ ឆ្នាំ ២០០២ ដោយមានសមាសភាពចូលរួមដូចតទៅ :

**ចៅក្រមជំនុំជំរះ**
លោក [redacted] ប្រធានតុលាការខេត្តកណ្តាល

**តំណាងអយ្យការ**
លោក [redacted] ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**
លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

**តំណាងមេធាវី**
លោក [redacted]

**ជើម្បីជំនុំជំរះ :**

-ឈ្មោះ **ចា សត** អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិនរាល ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃស្នាក់នៅតាមសួនច្បារ របររកស៊ី កម្មករសំណង់ នៅលីវ ឪពុកឈ្មោះ **ចា សជ** (ស្លាប់) ម្តាយ ឈ្មោះ **ឧ សរ** (រស់) ទោសពីមុន *គ្មាន* ។

-ឈ្មោះនេះត្រូវចាប់ខ្លួនកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ ត្រូវចោទពីបទប្លន់ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅចំណុចភូមិព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ ។

តាមរបាយការណ៍របស់អធិការនគរបាលខណ្ឌចំការមន រាជធានីភ្នំពេញ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០ និង ដីកាសន្និដ្ឋានស្ថាពរលេខ : ០៨១ ដកសព ចុះថ្ងៃទី ១៣ខែ មីនា ឆ្នាំ ២០០០ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល ។

**ការប្រព្រឹត្តរបស់ជនជាប់មានដូចតទៅ**

នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០០ ម៉ោងប្រហែល ០៨ ឈ្មោះ ធ ផ ជាជនរងគ្រោះបានទៅលេងផ្ទះបង ឈ្មោះ ញ គញ នៅភូមិព្រែកឯង ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្តាល ហើយបានសម្រាកដោយទុកម៉ូតូរបស់ខ្លួនម៉ាក C៧០

គុបពណ៌ទឹកសមុទ្រនៅក្រោមផ្ទះបងនោះមួយយប់ ។

នៅវេលាម៉ោងប្រហែលជា ១១យប់ ក្រុមចោរមួយក្រុមមានគ្នា ០៣នាក់ បានចូលទៅកាច់របងដែកផ្ទះលោក ញ គញ នោះ ហើយសែងម៉ូតូនោះលើករំលងរបងដែកមកក្រៅ ហើយកាច់ជន្ទល់ម៉ូតូដែលជាប់សោឱ្យរវៀចរួចជិះឌុបគ្នាសំដៅក្រុងភ្នំពេញ ប៉ុន្តែជិះបានបន្តិចម៉ូតូនោះអស់សាំង ហើយក៏បណ្តើរម៉ូតូនោះមកដល់ស្ពានច្បារអំពៅត្រូវកងរាជអាវុធហត្ថឆែកឆេររកកាតម៉ូតូ ។ គ្មានកាតម៉ូតូ ចោរពីនាក់បានសុំកងរាជអាវុធហត្ថទៅយកកាតម៉ូតូនៅឯផ្ទះហើយឆក់ឱកាសនេះគេចខ្លួនបាត់តែម្តង ។ នៅសល់ចោរម្នាក់ដែលនៅចាំម៉ូតូឈ្មោះ ឃ សគ បានសារភាពប្រាប់សមត្ថកិច្ចទៅក្រុមខ្លួនបានលួចម៉ូតូនេះមកពីស្រុកកៀនស្វាយ ។ ភ្លាមនោះសមត្ថកិច្ចបានចាប់ខ្លួនបញ្ជូនទៅតុលាការក្រុងភ្នំពេញនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ឃ សគ បានឆ្លើយថា នៅថ្ងៃកើតហេតុបំណងទៅហូបបាយនៅសួនថ្មី ពេលនោះមានមនុស្សពីរនាក់បបួលទៅហូបស្រានៅបូឌិញ ។ លុះហូបស្រាហើយ បបួលខ្ញុំជិះម៉ូតូឌុបទៅច្បារអំពៅឆ្លងស្ពានឆ្ពោយទៅកើត នៅម៉ោងប្រហែល ០៩យប់ ទៅដល់កន្លែងមួយមានក្លោងទ្វារស៊ីម៉ង់មានរូបប្រាសាទ ពេលនោះម៉ូតូឌុបចេញទៅវិញ រួចពួកខ្ញុំដើរចូលទៅក្នុងប្រហែលជិតមួយគីឡូ ទៅដល់គេឱ្យខ្ញុំអង្គុយចាំនៅមាត់ផ្លូវ ។ ពីរនាក់ដើរចូលទៅក្នុងបាត់ប្រហែលពីរបីម៉ោង ឃើញពីរនាក់បណ្តើរម៉ូតូគុបពណ៌ទឹកសមុទ្រ មើលឃើញដោយភ្លើងរបង ។ បណ្តើរមកដល់ថ្នល់ជាតិរួចជិះម៉ូតូជាមួយគ្នាអាខ្ពស់ជាអ្នកបើក ខ្ញុំជិះក្រោយបំផុត អាកណ្តាលកំពស់ប្រហែលគ្នាសំបុរស ។ ជិះបានបន្តិចអស់សាំងបានហៅរឺម៉កសណ្តោងដល់ស្ពានច្បារអំពៅបណ្តើរចូលហាង ( ឬ ជិតភ្លឺ) ។ ផឹកកាហ្វេរួចបណ្តើរម៉ូតូឆ្លងស្ពាន ដល់ចុងស្ពាន ត្រូវប៉េអឹមសួររកកាតគ្រីអាពីរនាក់ថាកាតគ្រីនៅផ្ទះ ។ ប៉េអឹមឱ្យទៅយកម្តងមួយៗរហូតអស់ពីរនាក់ ។ ខ្ញុំប្រាប់ប៉េអឹមថាម៉ូតូលួចគេ ។

-ជនរងគ្រោះឈ្មោះ ឆ ឋ បានឆ្លើយថា ខ្ញុំបានផ្ញើរលិខិតឱ្យអ្នករងគ្រោះឈ្មោះ ញ គញ រួចហើយ ។ ហើយនាពេលសវនាការជននេះក៏បានបញ្ជាក់ច្បាស់ថា ខ្លួនបានជួយលើកម៉ូតូអុកបំបាក់ជន្ទល់ដែលជាប់សោ ដើម្បីងាយស្រួលក្នុងការធ្វើដំណើរ ។

-តាមចម្លើយរបស់ឈ្មោះ ឆ ឋ ដែលជាជនរងគ្រោះបានបង្ហាញឱ្យឃើញថា ផ្ទះកើតហេតុមានរបងព័ទ្ធជុំវិញកំពស់ប្រហែល ២.៥០ម៉ែត្រ រួមទាំងមានចរឹងដែកផង ហើយនៅចំណុចលើកម៉ូតូឆ្លោះរបងមានបាក់បែកនូវចរឹងដែក ។ ចំណុចនេះល្មមជឿបានថា ការប្រព្រឹត្តរបស់ជនជាប់ចោទ ពិតជាមានការចូលរួម ពីសំណាក់ជនផ្សេងទៀតក្រៅឈ្មោះ ឃ ស ។

-ឈ្មោះ ឃ សគ បានឆ្លើយថា ខ្លួនឃើញច្បាស់ថាម៉ូតូដែលបក្ខពួកខ្លួនយកមានជាប់សោរជន្ទល់ ចំណុចនេះកាន់តែបញ្ជាក់ឱ្យឃើញថាឈ្មោះ ឃ សគ ពិតជាបានដឹងច្បាស់នូវអំពើរបស់បក្ខពួក និង មានចេតនាចូលរួមប្រព្រឹត្តបទល្មើសដោយពិតប្រាកដ ។

-ពិតមែនតែជនល្មើសពីរនាក់ទៀត ពុំមានសាវតាជាតិ ហើយត្រូវតំណាងអយ្យការបង្គង់បណ្តឹងអាជ្ញា ។ ប៉ុន្តែភស្តុតាងគួរល្មម និង បញ្ជាក់ឱ្យឃើញថា នៅក្នុងពេលប្រព្រឹត្តបទល្មើសមានមនុស្សបីនាក់ចូលរួម ។

-តាមកំណត់ហេតុឃាត់ខ្លួនរបស់អធិការនគរបាលខ័ណ្ឌចំការមន បានបញ្ជាក់ច្បាស់ថា ខ្លួនបានឃាត់ខ្លួនឈ្មោះ ឃ សគ តែជនពីរនាក់ទៀតរួមដំណើរបានគេចខ្លួនបាត់រួមទាំងម៉ូតូមួយគ្រឿងម៉ាក C៧០ គុបពណ៌ទឹកសមុទ្រលេខតួ C៧០-៨៣៨២៨៨០ លេខម៉ាស៊ីន C៧០ E៨៤០៨៤៨៦ លេខផ្លាក ២-៦៥២១ កណ ១ ។

-តាមប័ណ្ណសំគាល់ទោចក្រយានយន្ត បង្ហាញឱ្យឃើញថា ម៉ូតូម៉ាកហុងដាគុប C៧០ មានលេខដូចខាងលើជា

កម្មសិទ្ធិរបស់ឈ្មោះ ឆ ផ ។

-ជនរងគ្រោះឈ្មោះ ឆ ផ បានទទួលយកម៉ូតូវិញនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០ ។

-រាល់ភស្តុតាងខាងលើ បានបង្ហាញឱ្យឃើញថាឈ្មោះ **ម សត** បានចូលរួមជាមួយបក្ខពួកពីរនាក់ទៀត យកម៉ូតូរបស់ជនរងគ្រោះឈ្មោះ ឆ ផ នៅក្នុងលំនៅដ្ឋានដែលស្ថិតនៅភូមិមិត្តភាព ឃុំព្រែកឯង ស្រុកក្បៀនស្វាយ ខេត្តកណ្ដាល វេលាម៉ោងប្រហែល ២៣យប់ ឬ ២៤យប់ ដោយមានការកាច់បំបាក់ចំរឹងដែក និង សោរព្រម ទាំងជន្ទល់ម៉ូតូផង ។

-ភស្តុតាងនេះគួរល្មម និងបញ្ជាក់ឱ្យឃើញថា ពិតជាមានពិរុទ្ធភាពលើឈ្មោះ **ម សត** ក្នុងបទប្លន់ប្រព្រឹត្ត នៅភូមិមិត្តភាព ឃុំព្រែកឯង ស្រុកក្បៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ៣១ ខែ មករា ២០០០ វេលាម៉ោងប្រមាណ ២៣ ទៅ ២៤អាធ្រាត្រ ដូចដែលតំណាងអយ្យការចោទប្រកាន់ប្រាកដមែន ។ បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យ ផ្ដន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

មាត្រា ៣៤ មានចែងដូចតទៅ :

១-ជនណាដែលបានលួច ឬ ប៉ុនប៉ង នឹងលួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសទាំងនេះ ។

របងផ្ទះធ្វើពីស៊ីម៉ង់កំពស់ប្រហែល ០២ម៉ែត្រកន្លះខាងលើមានចំរឹងលំពែងកំពស់ប្រហែលជាងកន្លះម៉ែត្រ ពេល ម៉ោង ០៤ទៀបភ្លឺទៅមើលម៉ូតូទុកក្នុងរបងបាត់ ។ ពេលដើរមើលរបងបាក់លំពែងពីប្រវែងប្រហែលជាងពីរម៉ែត្រ ( ចំរឹងប្រហែល ២០ សង់ទីម៉ែតពីគ្នា ) ។

ម៉ូតូទទួលបានវិញនៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០ ។

ទាមទារសំណងចាយវាយរកម៉ូតូ អស់ពីរថ្ងៃមួយយប់អស់ ២០០ដុល្លា ជួយសាំងប៉េអឹមអស់ ២០០ដុល្លាការ ខាតបង់ពេលវេលា ១០០ដុល្លាជួសជុលម៉ូតូបែកស្គុប ៥០ដុល្លា ។ កន្លែងកើតហេតុភូមិមិត្តភាព ឃុំព្រែកឯងចុះពីផ្លូវជាតិ ប្រហែល ៣០០ម៉ែត្រទល់មុខផ្ទះឯកឧត្តម ស ខេង ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការ ការប្រព្រឹត្តរបស់ជនជាប់ចោទ បានឆ្លើយសារភាព ចំពោះមុខប៉េអឹម ។ ពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ ។ ហេតុនេះសុំតំកល់ លិខិតចោទប្រកាន់ ***លេខ ចុះថ្ងៃទី ខែ ឆ្នាំ*** ទុកជាបានការ ។

មេធាវីការពារឱ្យជនជាប់ចោទរក្សាសិទ្ធិនាពេលសវនាការ បានធ្វើសេចក្ដីសន្និដ្ឋានថា សុំឯកភាពតាមសេចក្ដី សន្និដ្ឋានរបស់តំណាងអយ្យការ ប៉ុន្តែសុំបន្ធូរបន្ថយលើសំណងរដ្ឋប្បវេណីឱ្យបាននៅទាប ព្រោះជនជាប់ចោទគ្មានមុខរបរ គ្មានទីលំនៅ ហើយម៉ូតូអ្នករងគ្រោះទទួលវិញរួចហើយ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី

-ក្រោយពីបានស្ដាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

**<u>តុលាការខេត្តកណ្ដាល</u>**

**<u>យល់ឃើញថា</u>**

-ជនជាប់ចោទឈ្មោះ **ចា សត** ជានីតិជនដែលអាចយល់ដឹងបានអំពីអំពើ និងការអន្តរាយដែលកើតចេញពីអំពើរបស់ខ្លួន ។

-ជនជាប់ចោទបានសារភាពថា នៅពេលដែលធ្វើដំណើរទៅកន្លែងហេតុ និងក្រោយពីពេលដែលបានបណ្ដើរម៉ូតូមានចូលរួមពីសំណាក់មនុស្សពីរនាក់ផ្សេងទៀត ។

-ជនជាប់ចោទបានព្យាយាមបិទបាំងនូវសាវតាជនទាំងពីរ ដោយពុំសមហេតុផលថា ខ្លួនមិនបានស្គាល់ជនដែលបានបបួលខ្លួន ជាមួយនិងការរួមដំណើរនោះឡើយ ។

-ជនជាប់ចោទបានព្យាយាមទាំងបំបាំងនូវសកម្មភាពរបស់ខ្លួនក្នុងការចូលរួមប្រព្រឹត្ត នាពេលសវនាការ ប៉ុន្តែនៅចំពោះមុខអយ្យការក្រុងភ្នំពេញឈ្មោះ **ចា សត** បានឆ្លើយច្បាស់ថា ខ្លួនបានជួយលើកម៉ូតូរបស់ជនរងគ្រោះ ដែលបក្ខពួកខ្លួនចូលទៅយក ផ្លោះរបងចេញមកក្រៅ ។

-ការលួចធ្វើដោយអំពើហិង្សា មានអាវុធ ឬ អត់អាវុធ បណ្ដាលឱ្យ ឬ មិនបណ្ដាលឱ្យរងរបួស ។

-ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬ ដោយមានគាស់ទំលុះទំលាយ ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្ដន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ០៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២-អំពើលួចប្លន់ ឬ ការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

-ជនរងគ្រោះ **ឆ ផ** បានប្ដឹងទាមទារសំណងជម្ងឺចិត្តជូសជុលការអន្តរាយ នៅប្រាក់ចំនួន ៥៥០ដុល្លាអាមេរិកក្នុងនោះមានប្រាក់ចំណាយក្នុងការស្វែងរកម៉ូតូ ២០០ដុល្លា ប្រាក់ចំណាយសម្រាប់ការហូបចុករបស់ប៉ូលីស ដែលបានប្រគល់ម៉ូតូ ២០០ដុល្លា ការខាតបង់ពេលវេលា ១០០ដុល្លា និង ជួសជុលម៉ូតូ ៥០ដុល្លា តុលាការគប្បីពិចារណា និងសម្រេចនូវការទាមទារណាដែលសមហេតុផល និងរាល់ការចំណាយដែលទទួលយកបាន ។

-ឈ្មោះ **ចា សត** ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ និង ឃុំខ្លួនបណ្ដោះអាសន្នកាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០០ ។

## <u>**ដោយហេតុនេះសំរេច**</u>

១-ផ្ដន្ទាទោស :

-ឈ្មោះ **ចា សត** ភេទប្រុស អាយុ ២៥ឆ្នាំ កំណត់ដាក់ពន្ធនាគារចំនួន ០៤ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ ពីបទប្លន់ប្រព្រឹត្តនៅភូមិមិត្តភាព ឃុំព្រែកឯង ស្រុកក្បៀនស្វាយ ខេត្តកណ្ដាលកាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០ ។

២-វត្ថុតាងមាន :

-មេសោម៉ាកសូឡិច ០១

-កូនសោ ០១

ត្រូវប្រគល់ឱ្យឈ្មោះ **ចា សត** វិញ ។

៣-បង្គាប់ឱ្យឈ្មោះ **ចា សត** សងសំណងជូសជុលការអន្តរាយនៅប្រាក់រៀលស្មើនឹងប្រាក់ ១០០ដុល្លាអាមេរិកទៅឱ្យឈ្មោះ **ឆ ផ** សុំលើសពីនេះបដិសេធចោល ។

ករណីរឹងទទឹងត្រូវដាក់គុកបង្ខំលើរូបរាងកាយតាមច្បាប់ ស្ដីពីការដាក់គុកបង្ខំលើរូបរាងកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

៤-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីនេះព្រះករុណា ព្រះចៅក្រុងកម្ពុជាទ្រង់បានបង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធ ត្រូវអនុវត្តសាលក្រមឱ្យបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*កណ្តាល, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០*

**បានឃើញ**
**ប្រធានតុលាការ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

តុលាការក្រុងភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦០២ ចុះថ្ងៃទី ១៩
ខែ វិច្ឆិកា ឆ្នាំ ២០០១
សាលក្រម
លេខ ៨៨ "ច" ចុះថ្ងៃទី ០៨
ខែ វិច្ឆិកា ឆ្នាំ ២០០២

---

សាលក្រមនេះបានចូលជាស្ថាពរហើយនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៣
ដោយគូភាគីពុំបានចូលមក ប្តឹងឧទ្ធរណ៍ក្នុងច្បាប់ ។
ភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៣
ក្រឡាបញ្ជី
[redacted]

## នាមនាមប្រជារាស្ត្រខ្មែរ
## តុលាការក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅសាលាជំរះក្តីតុលាការក្រុងភ្នំពេញកាលពីថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០២ ដែលមានសមាសភាពចូលរួម :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

**មេធាវីការពារ**

លោក [redacted] មេធាវីការពារជនជាប់ចោទ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ : ១៦០២ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដែលមានជនជាប់ចោទពីរនាក់ :

-ឈ្មោះ **ទ្ធិ** ៖ ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅផ្ទះលេខ ៦ សង្កាត់ផ្សារកណ្តាល I ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៦ ផ្លូវ ១៤៤ សង្កាត់ផ្សារកណ្តាល I ខណ្ឌដូនពេញ ក្រុងភ្នំពេញ នៅលីវ ឪពុកឈ្មោះ **ទ្ធិ អ** (រ) ម្តាយឈ្មោះ **ឃ ឈ** (រ) ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។

-ឈ្មោះ **ទ ទ** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករកាណូត កើតនៅភូមិរកាពុក ឃុំគ្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ សាសនាព្រះពុទ្ធ ទីលំនៅ មុនពេលចាប់ខ្លួនស្នាក់នៅលើកាណូត សង្កាត់ផ្សារកណ្តាល ១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ប្រពន្ធឈ្មោះ **ស ទា** លែងលះគ្នាមានកូន ០១នាក់ ឪពុកឈ្មោះ **ទ ទ** (រ) ម្តាយ ឈ្មោះ **ខ ឈ** (រ) ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។

ត្រូវចោទពី "**បទប្លន់**" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ : ១៦៥៧ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ របស់តំណាងអយ្យការក្រុងភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ : ៤០៤៧ តព្រ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២ របស់ចៅក្រមអង្កេតតុលាការក្រុងភ្នំពេញ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ : ៦២៩៧ តព្រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២ របស់ប្រធានតុលាការក្រុងភ្នំពេញ ។

-តំណាងអយ្យការបានធ្វើនូវសេចក្តីសន្និដ្ឋានចោទប្រកាន់ទោសលើឈ្មោះ **ម ម** និង ឈ្មោះ **ទ្ធិ រ** តាមដីកាសន្និដ្ឋានស្ថាពរលេខ : ១៦៥៧ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ **ម ម** បានឆ្លើយថា ខ្ញុំមានមុខរបរមុនចាប់ខ្លួន ជាអ្នកបកប្រែភាសាអង់គ្លេសអោយភ្ញៀវទេសចរណ៍បរទេសនៅលើកាណូតទេសចរណ៍នៅមុខវាំងឈ្មោះ **ម៉ារីយ៉ា** ។

នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ ម៉ោង ០៤ និង ៣៥ នាទីល្ងាច ខ្ញុំបានទៅដើរលេងមុខវាំងមាត់ទន្លេក៏បានជួបជាមួយជនរងគ្រោះ ជាជនបរទេសជនជាតិជប៉ុនកំពុងអង្គុយលេង ពេលនោះជនបរទេសនោះបាននិយាយជាភាសាអង់គ្លេសមកកាន់ខ្ញុំ អោយជួយជូនវាជិះកាណូតទេសចរណ៍ ដើរលេងនៅត្រើយម្ខាងពីមុខវាំង ដោយវាចង់ទៅមើលទេសភាព និងថតរូបនៅត្រើយម្ខាងពេលល្ងាច ។ ដោយខ្ញុំទំនេរក៏ព្រមជូនវាទៅ ពេលឡើងជិះទូកកាណូតនោះជនបរទេសនោះ ក៏បានហៅឈ្មោះ **ទ្ធិ រ** ភេទប្រុស អាយុប្រហែល ១៧ឆ្នាំ និង ឈ្មោះ **ម** ភេទប្រុស អាយុប្រហែល ២៣ឆ្នាំ ដែលនៅលេងក្បែរនោះដែរអោយឡើងជិះទូកទៅត្រើយម្ខាងដើរលេងដែរ នៅលើទូកខ្ញុំជជែកនិយាយភាសាអង់គ្លេសពីនេះពីនោះ ជាមួយជនបរទេសនោះ ឯឈ្មោះ **ម** ជនបរទេសនោះ អោយកាមេរ៉ាថតរូបរហូតដល់ត្រើយ ។ លុះដល់លើគោក ជនបរទេសនោះទារយកកាមេរ៉ាពីឈ្មោះ **ម** ថតម្តង ថតអស់ចិត្តក៏ហុចអោយឈ្មោះ **ម** ថតវិញ ។ លុះដល់ម៉ោង ០៧យប់ ជនបរទេសនោះ ក៏យកកាមេរ៉ាដាក់ចូលក្នុងកាបូបស្ពាយ រួចក៏ហុចអោយឈ្មោះ **ទ្ធិ រ** ស្ពាយដើរពីក្រោយជាមួយឈ្មោះ **ម** ។ ចំណែកខ្ញុំដើរខាងមុខជាមួយជប៉ុនជនរងគ្រោះនោះ ។ ពេលកំពុងដើរជាមួយជនរងគ្រោះខ្ញុំពុំបានដឹងថាឈ្មោះ **ទ្ធិ រ** យកកាបូបកាមេរ៉ារត់ទៅបាត់នោះទេ លុះពួជប៉ុននោះនិយាយសួរខ្ញុំទើបបានដឹងថា ឈ្មោះ **ទ្ធិ រ** បានយកកាបូបកាមេរ៉ារត់ទៅបាត់ហើយ ម្យ៉ាងទៅពេលនោះយប់ងងឹតបន្តិចទៅហើយពេលនោះក៏បាត់ឈ្មោះ **ទ្ធិ រ** ដែរ ។ ពេលនោះខ្ញុំក៏ប្រាប់ជនបរទេសនោះថា ឈ្មោះ **ទ្ធិ រ** ប្រហែលជាឈប់ទិញបារីហើយ ។

លុះពេលប្រហែលមួយម៉ោងក្រោយមកទៀតឈ្មោះ **ម** ក៏បញ្ជាអោយខ្ញុំជួយចាប់ជនរងគ្រោះ ដើម្បីអោយវាងាយស្រួលឆែក និង លូកហោប៉ៅដកយកសំភារះផ្សេងៗ ដែលនៅជាប់ខ្លួនជនរងគ្រោះ ពេលនោះខ្ញុំប្រកែកជំទាស់មិនយល់ព្រមធ្វើតាមបញ្ជារបស់វាទេ ម្យ៉ាងទៀតជាអំពើខុសច្បាប់នឹងខ្ញុំពុំដែលធ្វើអំពើខុសច្បាប់ពីមុនៗមកទេ ដោយឃើញខ្ញុំប្រកែកដូច្នេះឈ្មោះ **ម** ក៏គំរាមធ្វើបាប និង ដេញវ៉ៃខ្ញុំដោយភ័យខ្លាចវាគុំធ្វើបាប និង វ៉ៃខ្ញុំក៏ស្ទូតដើរអោយលឿនជាមួយជនរងគ្រោះ ប៉ុន្តែត្រូវឈ្មោះ **ម** ដេញតាមទាន់ ហើយចាប់ជនរងគ្រោះ ដោយជនរងគ្រោះក៏ខំរើបំរះដែរពេលនោះខ្ញុំក៏ឈប់ជួយជនរងគ្រោះកុំអោយឈ្មោះ **ម** ធ្វើបាប និង យកសំភារះគេ ប៉ុន្តែនៅមិនឈ្នះឈ្មោះ **ម** ទៀតពីព្រោះថាវាមានមាឌធំជាងបន្តិច ទីបំផុតឈ្មោះ **ម** ក៏ដកកាបូបពីខ្លួនជនរងគ្រោះបានកាបូបស្ពាយ និង សំភារះមួយចំនួនហើយរត់គេចបាត់តែម្តង ។ ចំពោះចម្លើយនៅចំពោះមុខសមត្ថកិច្ចប៉ូលីស និង នៅតុលាការ ខ្ញុំសូមបដិសេធ ពីព្រោះមានការបង្ខិតបង្ខំគំរាមវ៉ៃនៅប៉ូលីស និងខ្ញុំខ្លាចប៉ូលីសធ្វើបាប ពេលនៅតុលាការចេះតែឆ្លើយទៅ ។ គឺបដិសេធត្រង់ថា

ខ្ញុំពុំបានចូលរួមប្លន់យកសំភារៈជនបរទេសទេ ហើយក៏ពុំបានចូលរួមចាប់ដៃ ចាប់ជនរងគ្រោះអោយឈ្មោះ ម ដកហូតសំភារៈពីជនរងគ្រោះដែរ គឺនៅពេលនោះមានតែខ្ញុំប្រកែក និង ចូលទៅជួយទៅវិញទេ ។ ចំពោះ ម និង ឈ្មោះ ទ្និ រ ពីមុនៗពុំបានស្គាល់គ្នាដើរជាមួយគ្នាទេ ប៉ុន្តែចំពោះឈ្មោះ ម ខ្ញុំធ្លាប់ឮធ្លាប់ដឹងថា វាជាជើងល្អនៅមាត់ទន្លេមុខវាំង ហើយអ្នកទាំងពីរក៏ពុំមែនជាមិត្តភក្តិនឹងខ្ញុំដែរ ។

ចំពោះការចោទប្រកាន់មកលើខ្ញុំថា បានប្លន់យកសំភារៈរបស់ជនបរទេសនោះ ខ្ញុំសូមបដិសេធ ពីព្រោះពុំបានប្រព្រឹត្ត និង ពុំបានចូលរួមគំនិតជាមួយឈ្មោះ ម ទេ ។

ដោយឡែកចំពោះឈ្មោះ ទ្និ រ នេះ ពេលដើរលេងជាមួយជនរងគ្រោះ ខ្ញុំគ្រាន់តែដឹងថា វាត្រូវជនរងគ្រោះពឹងអោយជួយកាន់ និង ស្ពាយកាបូបដាក់កាមេរ៉ា ពេលត្រឡប់មកវិញ ហើយឆ្លៀតពេលជនបរទេសនោះប្រហែសភ្លេចខ្លួន វាក៏លួចយករួចរត់គេចខ្លួនមកមុនបាត់ គ្មានពីណាចូលរួមជាមួយវាទេ ។

ចំពោះសំភារៈទាំងអស់ដែលឈ្មោះ ទ្និ រ និងឈ្មោះ ម លួច និងប្លន់យកនោះ សមត្ថកិច្ចប៉ូលីសបានប្រគល់អោយជនរងគ្រោះវិញអស់ហើយ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនជាប់ចោទឈ្មោះ ម ម ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅចៅក្រមស៊ើប ។

-ជនជាប់ចោទឈ្មោះ ទ្និ រ បានឆ្លើយថា ខ្ញុំពុំបានមានគំនិតប្លន់យកសំភារៈ គឺកាបូប និង កាមេរ៉ារបស់ជនរងគ្រោះជាមួយឈ្មោះ ម ម និងឈ្មោះ ម ទេ ពីព្រោះខ្ញុំជាមួយឈ្មោះ ម ម និង ម ពុំដែលស្គាល់គ្នា រាប់អានគ្នា ឬមិត្តភក្តិគ្នាពីមុនមកទេ គឺជួបគ្នាដោយចៃដន្យនៅមាត់ទន្លេនៅថ្ងៃកើតហេតុ ។ ចំពោះការចោទប្រកាន់ខ្ញុំ ថាបានចូលរួមគ្នាប្លន់យកកាមេរ៉ាជនបរទេសជាមួយឈ្មោះ ម ម និង ឈ្មោះ ម គឺខ្ញុំសូមបដិសេធ ពីព្រោះក្នុងរឿងនេះ ពេលដើរលេងទៅត្រើយម្ខាង គឺជនបរទេសនោះបានហុចកាបូប ដែលមានដាក់កាមេរ៉ាមួយគ្រឿងក្នុងនោះអោយខ្ញុំជួយកាន់ អោយដោយឈ្មោះ ម ម ដើរនៅខាងមុខជាមួយជនបរទេស រីឯឈ្មោះ ម ដើរបន្ទាប់មកខាងក្រោយ ហើយខ្ញុំដើរតាមពីក្រោយ ។ លុះដល់កន្លែងស្ងាត់បន្តិច ខ្ញុំក៏លួចរត់គេចពីពួកគេទាំងអស់តែម្តង ដោយឈ្មោះ ម ម ឈ្មោះ ម និង ជនបរទេសនោះពុំបានដឹងផង ។ កាមេរ៉ានោះ ខ្ញុំបានប្រគល់អោយម្ចាស់ទៅវិញហើយ ពេលសមត្ថកិច្ចចាប់ខ្ញុំបាន ។ ចំពោះការលួចយកកាមេរ៉ារបស់ជនបរទេសនោះ គឺឈ្មោះ ម ម និង ឈ្មោះ ម ពុំបានដឹង និង បានចូលរួមជាមួយខ្ញុំទេ ។ ខ្ញុំពុំបានប្លន់គេទេ គ្រាន់តែលួចយករបស់គេប៉ុណ្ណោះ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅចៅក្រមអង្កេត ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសាកសួរបំភ្លឺរបស់ជនរងគ្រោះឈ្មោះ W Y N ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១ និង ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។

-ក្រឡាបញ្ជីបានអានកំណត់ហេតុប្រគល់សំភារៈ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

-ក្រឡាបញ្ជីបានអានរបាយការណ៍ ករណីបង្ក្រាបមុខសញ្ញាចោរប្លន់ ជនបរទេសរបស់អធិការដ្ឋាននគរបាលខណ្ឌដូនពេញ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។

-ក្រឡាបញ្ជីបានអានរបាយការណ៍លេខ : ០៩២ ស.ណ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ការិយាល័យប៉ូលីសជនបរទេស នៃស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសថា ឆ្លងតាមការជជែកដេញដោលនាពេលនេះ ឃើញថាជនជាប់ចោទទាំងពីរបានឆ្លើយដោះសារពុំព្រមឆ្លើយសារភាពនូវការពិត ដែលខ្លួនបានប្រព្រឹត្តលើជនរងគ្រោះមិនតែប៉ុណ្ណោះបានឆ្លើយបដិសេធនូវចម្លើយ នៅចំពោះមុខសមត្ថកិច្ចប៉ូលីសយុត្តិធម៌ និងនៅស្ថាប័នតុលាការទៀត ។ ឆ្លងតាមការ

ពិនិត្យពីពាក្យបណ្ដឹងជនរងគ្រោះ ពិនិត្យលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងលើចម្លើយរបស់ជនជាប់ចោទទាំងពីរនៅចំពោះមុខសមត្ថកិច្ចនគរបាលយុត្តិធម៌ និង នៅចំពោះមុខតុលាការ ព្រមទាំងផ្អែកលើសំភារៈវត្ថុតាងផ្សេងៗ តំណាងអយ្យការយល់ឃើញថា កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០១ ម៉ោង ០៨យប់ នៅត្រើយម្ខាងនៃមាត់ទន្លេមុខវាំងពិតជាមានអំពើប្លន់យកសំភារៈលើជនរងគ្រោះ ដែលជាជនបរទេសឈ្មោះ W Y N ពិតប្រាកដមែន ដែលប្រព្រឹត្តដោយជនជាប់ចោទទាំងពីរនេះ ។

ដូច្នេះក្នុងនាមតំណាងអយ្យការ សូមរក្សានូវការចោទប្រកាន់ទោសលើឈ្មោះ ម ម និង ឈ្មោះ ទ្វិ ៖ ពីបទប្លន់ដដែល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ដោយឡែកចំពោះឈ្មោះ ម តំណាងអយ្យការសូមធ្វើការបង្គង់បណ្ដឹងអាជ្ញាទុកមួយអន្លើសិនរង់ចាំមានសាវតារជាតិ ។

-មេធាវីលោក[redacted] សុខា បានឆ្លើយថា ឆ្លងតាមការសួរដេញដោលលើកូនក្ដីខ្ញុំទាំងពីរ ខ្ញុំបាទសូមសន្និដ្ឋានចំពោះកូនក្ដីខ្ញុំឈ្មោះ ទ្វិ ៖ ថា នាពេលសវនាការឈ្មោះ ម ម បានបញ្ជាក់ថា ពុំបានប្រព្រឹត្តអំពើប្លន់ជាមួយឈ្មោះ ទ្វិ ៖ និងឈ្មោះ ម ទេ គឺឈ្មោះ ម និងឈ្មោះ ទ្វិ ៖ ខ្លួនពុំដែលស្គាល់គ្នាពីមុនមកទេ ទើបនិងស្គាល់នៅថ្ងៃកើតហេតុហើយការចាប់ជនរងគ្រោះ ដកហូតយកសំភារៈពីក្នុងខ្លួនជនរងគ្រោះនោះគឺ ឈ្មោះ ម តែម្នាក់ឯងប៉ុណ្ណោះ ។ ចំពោះឈ្មោះ ទ្វិ ៖ ពុំបានចូលរួមជាមួយឈ្មោះ ម ចាប់ជនរងគ្រោះដោះយកសំភារៈទេ តែឈ្មោះ ទ្វិ ៖ បានលួចយកកាមេរ៉ាដែលជនរងគ្រោះពឹងអោយជួយស្ពាយ ដោយរត់គេចចេញពីជនរងគ្រោះ និងឈ្មោះ ម ម មកមុនមិនដឹងទៅណា ។ ក្រោយពេលឈ្មោះ ទ្វិ ៖ លួចយកកាមេរ៉ា ដែលជនរងគ្រោះពឹងអោយឈ្មោះនេះស្ពាយរត់គេចយកមកមុនប្រហែលកន្លះម៉ោង ក្រោយមកឈ្មោះ ម ក៏គំរាមមកលើឈ្មោះ ម ម អោយជួយចាប់ជនរងគ្រោះ ដែលកំពុងដើរជាមួយគ្នាដើម្បីងាយស្រួលឈ្មោះ ម ចូលមកដោះយកសំភារៈ និង កាបូបស្ពាយរបស់ជនរងគ្រោះ ប៉ុន្តែឈ្មោះ ម ម ពុំយល់ព្រមតាមបញ្ជារបស់ឈ្មោះ ម ហើយនៅពេលដែលឃើញឈ្មោះ ម ចូលមកចាប់ជនរងគ្រោះប្រតាយប្រតប់ដោះយកសំភារៈក៏ឈ្មោះ ម ម ចូលមកជួយជនរងគ្រោះ ដើម្បីកុំអោយ ម ធ្វើបាប និង ដោះយកសំភារៈ ប៉ុន្តែនៅជួយពុំឈ្នះពីព្រោះឈ្មោះ ម មានមាឌធំ ហើយឈ្មោះ ម បានដោះយកសំភារៈពីជនរងគ្រោះបានអស់ហើយ ហើយរត់គេចទៅបាត់ ។ នេះជាអង្គហេតុដែលកូនក្ដីខ្ញុំបាទបានឆ្លើយនៅពេលសវនាការនេះ ។ ដោយឡែកចំពោះឈ្មោះ ទ្វិ ៖ បានឆ្លើយថា ខ្លួនពុំបានប្លន់យកកាមេរ៉ាជនបរទេសនោះទេ គឺខ្លួនគ្រាន់តែបានលួចយកកាមេរ៉ាដែលជនបរទេសនោះពឹងអោយជួយស្ពាយប៉ុណ្ណោះ ហើយកាបូបនេះ គឺខ្លួនធ្វើតែម្នាក់ឯងប៉ុណ្ណោះ ពុំមានឈ្មោះ ម ម និង ឈ្មោះ ម បញ្ជា ឬ ចូលរួមគំនិតទេ គឺពេលខ្ញុំលួចយកកាមេរ៉ានោះ គឺឈ្មោះ ម ម និងឈ្មោះ ម ដើរពីខាងមុខជាមួយជនរងគ្រោះ និង ឈ្មោះ ម ដើរខាងក្រោយពុំបានដឹងផង ។

ម្យ៉ាងបើនិយាយធាតុចេតនារបស់កូនក្ដីខ្ញុំបាទទាំងពីរ គឺម្នាក់ៗសុទ្ធតែឆ្លើយបដិសេធចម្លើយនៅប៉ូលីសពីព្រោះមានការគំរាមបង្ខិតបង្ខំរឺធ្វើបាប ។ ហើយនៅតុលាការមានប៉ូលីសអង្គុយក្បែរទៀត ។

ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារជនជាប់ចោទទាំងពីរ សូមតុលាការមេត្តាលើកលែងការចោទប្រកាន់កូនក្ដីខ្ញុំឈ្មោះ ម ម ពីបទប្លន់ ហើយចំពោះឈ្មោះ ទ្វិ ៖ សូមតុលាការកែប្រែបទល្មើសពីប្លន់មកលួចវិញ ដោយឈរលើគតិច្បាប់ ។ ម្យ៉ាងកូនក្ដីខ្ញុំឈ្មោះ ទ្វិ ៖ ជាអនីតិជន ហើយការឃុំខ្លួនក៏ហួសនីតិវិធី និងគ្នាទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។ រីឯឈ្មោះ ម ម ក៏ដូច្នេះដែរ គឺជាអ្នកមានចំណេះដឹងគួរសម ការឃុំខ្លួនហួសនីតិវិធី ។

-ជនជាប់ចោទឈ្មោះ ម ម បាននិយាយសំដីចុងក្រោយថា សុំតុលាការមេត្តាលើកលែងការចោទប្រកាន់ទោស ពីព្រោះខ្លួនពុំបានប្រព្រឹត្តអំពើប្លន់អ្វីទេ និងដោះលែងអោយមានសេរីភាពវិញជួបជុំបងប្អូន ។

-ជនជាប់ចោទឈ្មោះ ទ្វ រ បាននិយាយសំដីចុងក្រោយថា សុំតុលាការមេត្តាបន្ធូរបន្ថយទោសអោយផង ពីព្រោះខ្លួនបានដឹងកំហុសហើយ ។

## តុលាការក្រុងភ្នំពេញ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរ

-ក្រោយពីបានស្តាប់ការអានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ការអានរបាយការណ៍មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវី

-ក្រោយពីបានស្តាប់សេចក្តីសំដីចុងក្រោយជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ ម ម និងឈ្មោះ ទ្វ រ បានត្រូវចោទ **ពីបទប្លន់** "លួចកាមេរ៉ា និង សំភារៈ" ពីជនបរទេស ក្នុងកាលៈទេសៈផ្សេងគ្នា នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ នៅត្រើយម្ខាងនៃមាត់ទន្លេមុខវាំង មុនក្រោយកន្លះម៉ោង ។

-នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ ម៉ោងប្រមាណ ០៧យប់ ពេលដែលឈ្មោះ ម ម ឈ្មោះ ម កំពុងដើរជាមួយជនរងគ្រោះ គឺឈ្មោះ ម ម ដើរជាមួយជនរងគ្រោះនៅខាងមុខ រីឯឈ្មោះ ម ដើរខាងក្រោយជាបន្ទាប់ជាមួយឈ្មោះ ទ្វ រ ដែលស្តាយកាបូបដាក់កាមេរ៉ាចំនួន ០១គ្រឿងផងនោះ គឺឆ្លៀតពេលឈ្មោះ ម ម ឈ្មោះ ម និងជនរងគ្រោះកំពុងដើរភ្លេចខ្លួនឈ្មោះ ទ្វ រ ក៏ឆ្លៀតពេលស្តាយកាមេរ៉ា ដែលជារបស់ជនរងគ្រោះយករត់គេចខ្លួនបាត់ពីអ្នកទាំងបីបាត់មិនដឹងទៅណា ។

-តាមចម្លើយជនជាប់ចោទឈ្មោះ ម ម និង ឈ្មោះ ទ្វ រ បញ្ជាក់ឱ្យឃើញថា ពួកខ្លួន និងឈ្មោះ ម ដែលស្គាល់គ្នាពីមុនមកនេះ ហើយនៅថ្ងៃកើតហេតុក៏ពួកខ្លួនទាំង ៣ ពុំបានសមគំនិតគ្នាទេ គំរោងការប្លន់យកសំភារៈរបស់ជនរងគ្រោះនោះដែរ គឺពេលកំពុងដើរឈ្មោះ ទ្វ រ ដែលជនរងគ្រោះពឹងឱ្យជួយស្តាយកាបូបកាមេរ៉ាក៏ឆ្លៀតយករត់គេចបាត់ ដោយខ្លួនឯងម្នាក់ប៉ុណ្ណោះ ពុំមានការសមគំនិត និងបញ្ជា ឬ ចូលរួមពីឈ្មោះ ម ម និង ឈ្មោះ ម ទេ ដែលនេះបញ្ជាក់ឱ្យឃើញថា ឈ្មោះ ទ្វ រ ពុំមានពាក់ព័ន្ធក្នុងអំពើប្លន់ទេ តែជាអំពើលួចសុទ្ធសាធ គប្បីកែប្រែបទប្លន់មកលួចវិញ ។

-ក្នុងរយៈពេលក្រោយកន្លះម៉ោងពីឈ្មោះ ទ្វ រ លួចយកកាបូបស្តាយមានកាមេរ៉ា ក្នុងនោះរត់គេចខ្លួនបាត់មកស្រាប់តែឈ្មោះ ម បញ្ជាឱ្យឈ្មោះ ម ម ជួយខ្លួនក្នុងការចាប់ជនរងគ្រោះ ដើម្បីខ្លួនបានដោះយកសំភារៈ និង កាបូបស្តាយមួយផ្សេងរបស់ជនរងគ្រោះ ដោយភ័យខ្លាចឈ្មោះ ម រៃធ្វើបាបឈ្មោះ ម ម ក៏យល់ព្រមជួយចាប់ជនរងគ្រោះ

ហើយឈ្មោះ ម ក៏ចូលមកដោះយកសំភារៈ និង កាបូបពីជនរងគ្រោះ ហើយរត់គេចបាត់តែម្តង ដែលនេះជាអំពើហឹង្សា ចាប់ជនរងគ្រោះដោះយកសំភារៈ ដោយចេតនាក្នុងអំពើប្លន់ពិតប្រាកដមែន ។

-គប្បីកែប្រែបទចោទពីបទប្លន់មកជាបទលួចវិញ លើជនជាប់ចោទឈ្មោះ ទ្ធិ រ ហើយពិរុទ្ធភាពគ្រប់គ្រាន់ លើឈ្មោះ ម ម ពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០១ ។

-ជនជាប់ចោទទាំងនេះ ជាយុវវ័យក្មេងៗពុំមានការអប់រំ ខ្វះការយល់ដឹង ហើយពុំធ្លាប់មានទោសពីមុនឡើយ គប្បីផ្តល់ស្ថានសំរាលទោសតាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-សំភារៈជនរងគ្រោះបានទទួលរួចហើយ តុលាការគប្បីពុំពិចារណា ។

## ហេតុនេះខ្មែរសម្រេច

១-កែប្រែបទចោទលើឈ្មោះ ទ្ធិ រ ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ដែលបានចោទប្រកាន់ពីបទប្លន់ តាមមាត្រា ៣៤ មកជាបទលួច តាមមាត្រា ៤៣ វិញ តាមអំណាចមាត្រា ១០៥ នៃច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌ ។

២-ផ្តន្ទាទោសលើឈ្មោះ ទ្ធិ រ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ខែ ( ដប់ប្រាំបីខែ ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០១ ពីបទចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០១ តាមមាត្រា ៤៣ និងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ផ្តន្ទាទោសលើឈ្មោះ ម ម ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ឆ្នាំ ( បួនឆ្នាំ ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០១ ពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០១ តាមមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤-ទុកសិទ្ធិអោយជនរងគ្រោះប្តឹងទារសំណងផ្សេងៗនៅពេលក្រោយបាន ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ ចំពោះមុខមេធាវីជនជាប់ចោទ សម្រេចបើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

[redacted]